នាយកដ្ឋាន នីតិវិធី
ចូល
លេខ:.004.........
ថ្ងៃទី០១/១២ ម៉ោង:១០
បញ្ជូនទៅ:..................

នស/រកម/០១១២/004

# ព្រះរាជក្រម

## យើង

### ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
### សមានភូមិជាតិសាសនា រក្សតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
### ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
### ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## ប្រកាសឲ្យប្រើ

ច្បាប់ ស្តីពីលទ្ធកម្មសាធារណៈ ដែលរដ្ឋសភាបានអនុម័ត កាលពីថ្ងៃទី០៣ ខែមករា ឆ្នាំ២០១២ នាសម័យប្រជុំរដ្ឋសភាលើកទី៧ នីតិកាលទី៤ និងដែលព្រឹទ្ធសភាពុំមានពេលវេលាគ្រប់គ្រាន់ក្នុងការពិនិត្យ និងឲ្យយោបល់លើអត្ថបទច្បាប់នេះឡើយ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ ៖

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

# ច្បាប់

# ស្តីពី

# លទ្ធកម្មសាធារណៈ

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

# ជំពូកទី ១
# បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

ច្បាប់នេះមានគោលបំណងធានាឲ្យដំណើរការលទ្ធកម្មសាធារណៈសម្រាប់ការទិញ ការសាងសង់ ការជួសជុល ការផ្តល់សេវាកម្ម និងការផ្តល់សេវាទីប្រឹក្សា ប្រព្រឹត្តទៅប្រកបដោយតម្លាភាព គណនេយ្យភាព ភាពយុត្តិធម៌ ប្រសិទ្ធភាព គុណភាព សមភាព ការសន្សំសំចៃ និងភាពទាន់ពេលវេលា ព្រមទាំងធានាឲ្យបាននូវប្រព័ន្ធលទ្ធកម្មសាធារណៈឯកភាពមួយនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ២.-**

ច្បាប់នេះមានគោលដៅកំណត់អំពីវិធាន វិធីសាស្ត្រ នីតិវិធី និងរចនាសម្ព័ន្ធសម្រាប់គ្រប់គ្រង និងអនុវត្តគ្រប់កិច្ចលទ្ធកម្មសាធារណៈនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ៣.-**

ច្បាប់នេះមានវិសាលភាពអនុវត្តចំពោះគ្រប់កិច្ចលទ្ធកម្មសាធារណៈនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដោយមិនគិតពីប្រភពធនធាន លើកលែងតែ :

- កិច្ចលទ្ធកម្មក្រោមគម្រោងហិរញ្ញប្បទានដោយដៃគូអភិវឌ្ឍ ដែលត្រូវអនុវត្តតាមគោលការណ៍ណែនាំនិងនីតិវិធីដូចមានចែងក្នុងកិច្ចព្រមព្រៀងហិរញ្ញប្បទាន ។ ប្រសិនបើកិច្ចព្រមព្រៀងមិនបានកំណត់អំពីគោលការណ៍ណែនាំនិងនីតិវិធីលទ្ធកម្មណាមួយផ្សេងទេ ដំណើរការលទ្ធកម្មត្រូវអនុវត្តតាមបទប្បញ្ញត្តិនៃច្បាប់នេះ ។
- លទ្ធកម្មដែលប៉ះពាល់ដល់ការសម្ងាត់ក្នុងវិស័យការពារជាតិ និងសន្តិសុខសាធារណៈ ដែលត្រូវមានការសម្រេចពីនាយករដ្ឋមន្ត្រី ។
- ការផ្តល់សម្បទានផ្សេងៗរបស់រដ្ឋ ដែលត្រូវអនុលោមតាមច្បាប់និងបទប្បញ្ញត្តិដោយឡែក ។

**មាត្រា ៤.-**

និយមន័យនៃបច្ចេកសព្ទដែលប្រើប្រាស់ក្នុងច្បាប់នេះ ត្រូវបានកំណត់ដោយសទ្ទានុក្រមដែលជាឧបសម្ព័ន្ធនៃច្បាប់នេះ ។

# ជំពូកទី ២
# ស្ថាប័នគ្រប់គ្រងលទ្ធកម្មសាធារណៈ

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ជាស្ថាប័នមានសមត្ថកិច្ចក្នុងការគ្រប់គ្រងលទ្ធកម្មសាធារណៈ និង

មានសិទ្ធិអំណាចរៀបចំគោលនយោបាយលទ្ធកម្មសាធារណៈ ព្រមទាំងអនុវត្តសិទ្ធិអំណាច ដែលមានកំណត់ក្នុងច្បាប់នេះ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធផ្សេងទៀត ។

**មាត្រា ៦.-**

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវមានអគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈជាសេនាធិការក្នុងការគ្រប់គ្រងលទ្ធកម្មសាធារណៈនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

## ជំពូកទី ៣
## ការទទួលខុសត្រូវរបស់ស្ថាប័នអនុវត្តលទ្ធកម្ម

**មាត្រា ៧.-**

ប្រធានស្ថាប័នអនុវត្តលទ្ធកម្ម ត្រូវគ្រប់គ្រងនិងដឹកនាំការអនុវត្តកិច្ចលទ្ធកម្មសាធារណៈឲ្យបានត្រឹមត្រូវតាមបទប្បញ្ញត្តិនៃច្បាប់នេះ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធផ្សេងទៀត ។

**មាត្រា ៨.-**

គ្រប់ស្ថាប័នអនុវត្តលទ្ធកម្ម ត្រូវបង្កើតគណៈកម្មាធិការលទ្ធកម្មមួយ ដើម្បីទទួលខុសត្រូវត្រួតពិនិត្យលើផែនការលទ្ធកម្ម និងឯកសារដេញថ្លៃ ធ្វើការវាយតម្លៃប្រគល់កិច្ចសន្យា គ្រប់គ្រងការអនុវត្តកិច្ចសន្យា និងដោះស្រាយបណ្តឹងតវ៉ាលទ្ធកម្មតាមសមត្ថកិច្ចរបស់ខ្លួន ។

ប្រធានស្ថាប័នអនុវត្តលទ្ធកម្មជាប្រធានគណៈកម្មាធិការលទ្ធកម្ម ។

នីតិវិធីនៃការបង្កើតគណៈកម្មាធិការលទ្ធកម្ម ត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ៩.-**

ស្ថាប័នអនុវត្តលទ្ធកម្ម ត្រូវមានអង្គភាពលទ្ធកម្មមួយដែលមានរចនាសម្ព័ន្ធច្បាស់លាស់ និងមានមន្ត្រីមានសមត្ថភាពជំនាញផ្នែកលទ្ធកម្មសាធារណៈគ្រប់គ្រាន់ ព្រមទាំងមានសិទ្ធិអំណាចសមស្របដើម្បីទទួលខុសត្រូវអនុវត្តរាល់កិច្ចលទ្ធកម្មសាធារណៈ ។

អង្គភាពលទ្ធកម្មមានរចនាសម្ព័ន្ធស្ថិតក្រោមប្រធានស្ថាប័នផ្ទាល់ និងជាសេនាធិការឲ្យគណៈកម្មាធិការលទ្ធកម្ម ។ អង្គភាពលទ្ធកម្មត្រូវដឹកនាំដោយប្រធានមួយរូបដែលមិនត្រូវមានតួនាទី និងភារកិច្ចពាក់ព័ន្ធនឹងកិច្ចការហិរញ្ញវត្ថុផ្សេងទៀតក្នុងស្ថាប័នរបស់ខ្លួនឡើយ ។ ប្រធានអង្គភាពលទ្ធកម្មជាលេខាធិការរបស់គណៈកម្មាធិការលទ្ធកម្ម ។

នីតិវិធីនៃការបង្កើត ការរៀបចំ និងការប្រព្រឹត្តទៅនៃអង្គភាពលទ្ធកម្មត្រូវកំណត់ដោយអនុក្រឹត្យ ។

ក្នុងករណីដែលអង្គភាពថវិកាត្រូវបានទទួលសិទ្ធិជាអាណាប័កផ្ទេរសិទ្ធិពីអាណាប័កដើមខ្សែនៃក្រសួង ស្ថាប័ន រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុអាចចេញប្រកាសផ្ទេរសិទ្ធិអំណាចតាមការចាំបាច់ទៅឲ្យអង្គភាពថវិកានៃក្រសួង ស្ថាប័ននោះដើម្បីអនុវត្តកិច្ចលទ្ធកម្ម ។

# ជំពូកទី ៤
# វិធីសាស្ត្រលទ្ធកម្មទំនិញ សំណង់ និងសេវាកម្ម

**មាត្រា ១០.-**

វិធីសាស្ត្រលទ្ធកម្មទំនិញ សំណង់ និងសេវាកម្ម ត្រូវធ្វើឡើងដោយអនុលោមតាមមាត្រា ១១ មាត្រា ១២ និងមាត្រា ១៣ នៃច្បាប់នេះ ។ លក្ខខណ្ឌ កម្រិតទឹកប្រាក់ និងនីតិវិធីសម្រាប់អនុវត្តវិធីសាស្ត្រលទ្ធកម្មនីមួយៗ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

**មាត្រា ១១.-**

វិធីសាស្ត្រដេញថ្លៃដោយប្រកួតប្រជែងជាសាធារណៈ ជាវិធីសាស្ត្រលទ្ធកម្មសម្រាប់ជ្រើសរើសអ្នកផ្គត់ផ្គង់ទំនិញ អ្នកទទួលការសំណង់ ឬអ្នកផ្តល់សេវាកម្ម ដោយបើកចំហចំពោះគ្រប់អ្នកដេញថ្លៃក្នុងស្រុក និងអន្តរជាតិ ។ វិធីសាស្ត្រដេញថ្លៃដោយប្រកួតប្រជែងជាសាធារណៈជាវិធីសាស្ត្រលទ្ធកម្មដែលមានកម្រិតតម្លាភាពខ្ពស់ និងដែលត្រូវជំរុញឲ្យប្រើក្នុងកិច្ចលទ្ធកម្មសាធារណៈ ។ វិធីសាស្ត្រដេញថ្លៃដោយប្រកួតប្រជែងជាសាធារណៈ រួមមាន :

ក- ការដេញថ្លៃដោយប្រកួតប្រជែងជាលក្ខណៈអន្តរជាតិ : វិធីសាស្ត្រនេះត្រូវប្រើសម្រាប់គម្រោងលទ្ធកម្មដែលមានទឹកប្រាក់កម្រិតធំ និងមានលក្ខណៈបច្ចេកទេសខ្ពស់ ។

ខ- ការដេញថ្លៃដោយប្រកួតប្រជែងក្នុងស្រុក : វិធីសាស្ត្រនេះត្រូវប្រើក្នុងករណីដែលមានផលិតផល ផលិតកម្ម សេវាកម្ម ឬសមត្ថភាពសាងសង់ក្នុងស្រុកគ្រប់គ្រាន់ ។

**មាត្រា ១២.-**

វិធីសាស្ត្រដេញថ្លៃដោយប្រកួតប្រជែងដទៃទៀត ជាវិធីសាស្ត្រលទ្ធកម្មដែលមិនមែនជាការដេញថ្លៃដោយប្រកួតប្រជែងជាសាធារណៈ រួមមាន :

ក- ការដេញថ្លៃមានកម្រិត ជាវិធីសាស្ត្រលទ្ធកម្មសម្រាប់ជ្រើសរើសអ្នកផ្គត់ផ្គង់ទំនិញ អ្នកទទួលការសំណង់ ឬអ្នកផ្តល់សេវាកម្ម ដែលត្រូវបានប្រើសម្រាប់មុខសញ្ញាលទ្ធកម្មគន្លឹះមានលក្ខណៈបច្ចេកទេសស្មុគស្មាញ មិនអាចរៀបចំបច្ចេកទេសទុកជាមុន និងមានអ្នកដេញថ្លៃតិចតួចដែលមានសមត្ថភាព ។ វិធីសាស្ត្រនេះតម្រូវឲ្យមានការធ្វើបុរេលក្ខណសម្បត្តិ ។

ខ- ការពិគ្រោះថ្លៃ ជាវិធីសាស្ត្រលទ្ធកម្មសម្រាប់ជ្រើសរើសអ្នកផ្គត់ផ្គង់ទំនិញ អ្នកទទួលការសំណង់ ឬអ្នកផ្តល់សេវាកម្ម ដែលត្រូវបានប្រើសម្រាប់មុខសញ្ញាលទ្ធកម្មមានរួចជាស្រេចនៅលើទីផ្សារក្នុងស្រុក និងមានទឹកប្រាក់មធ្យម ។

គ- ការស្ទង់តម្លៃ ជាវិធីសាស្ត្រលទ្ធកម្មសម្រាប់ជ្រើសរើសអ្នកផ្គត់ផ្គង់ទំនិញ អ្នកទទួលការសំណង់ ឬអ្នកផ្តល់សេវាកម្ម ដែលត្រូវបានប្រើនៅពេលមុខសញ្ញាលទ្ធកម្មមានរួចជាស្រេចនៅលើទីផ្សារក្នុងស្រុក និងមានទឹកប្រាក់ទាប ។

មាត្រា ១៣.-

វិធីសាស្ត្រលទ្ធកម្មដោយឡែក ត្រូវប្រើសម្រាប់ជ្រើសរើសអ្នកផ្គត់ផ្គង់ទំនិញ អ្នកទទួលការសំណង់ ឬអ្នកផ្ដល់សេវាកម្ម ដោយមិនមានការដេញថ្លៃ ។ វិធីសាស្ត្រនេះអាចអនុវត្តបាន លុះត្រាតែមានការអនុញ្ញាតជាមុនពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។ វិធីសាស្ត្រលទ្ធកម្មដោយឡែក រួមមាន :

ក- ការចុះកិច្ចសន្យាផ្ទាល់ ជាវិធីសាស្ត្រលទ្ធកម្មដែលតម្រូវឲ្យចរចាថ្លៃនិងបច្ចេកទេសផ្ទាល់ជាមួយនឹងអ្នកផ្គត់ផ្គង់ទំនិញ អ្នកទទួលការសំណង់ ឬអ្នកផ្ដល់សេវាកម្មក្នុងកាលៈទេសៈណាមួយដូចខាងក្រោម :

- មុខសញ្ញាលទ្ធកម្មមានប្រភពតែមួយ

- មុខសញ្ញាលទ្ធកម្មដែលត្រូវបានដេញថ្លៃដោយប្រកួតប្រជែងជាសាធារណៈម្ដងរួចមកហើយ ហើយជាតម្រូវការចាំបាច់បន្ទាន់ និងមិនមានពេលគ្រប់គ្រាន់សម្រាប់ធ្វើការដេញថ្លៃដោយប្រកួតប្រជែងជាសាធារណៈលើកទី ២

- ការដេញថ្លៃដោយប្រកួតប្រជែងជាសាធារណៈលើកទី ២ មិនទទួលបានជោគជ័យ

- តម្រូវការចាំបាច់បន្ទាន់ក្នុងពេលមានគ្រោះមហន្តរាយធម្មជាតិ ឬគ្រោះអាសន្នផ្សេងទៀត ហើយមានរយៈពេលខ្លីមិនអាចរង់ចាំឲ្យប្រើវិធីសាស្ត្រផ្សេងទៀតបាន

- សម្រាប់គោលបំណងសិក្សាស្រាវជ្រាវ ដកបទពិសោធ ឬអភិវឌ្ឍ ។

ខ- ការបន្តចុះកិច្ចសន្យា ជាវិធីសាស្ត្រលទ្ធកម្មដែលតម្រូវឲ្យចរចាថ្លៃនិងបច្ចេកទេសផ្ទាល់ជាមួយនឹងអ្នកផ្គត់ផ្គង់ទំនិញ អ្នកទទួលការសំណង់ ឬអ្នកផ្ដល់សេវាកម្មក្នុងកាលៈទេសៈដូចខាងក្រោម :

- មុខសញ្ញាលទ្ធកម្មដូចគ្នានឹងមុខសញ្ញាលទ្ធកម្មក្នុងកិច្ចសន្យាដើម ដែលទទួលបានតាមរយៈការដេញថ្លៃ

- ស្ថិតក្នុងអំឡុងពេលមិនលើសពី ៦ (ប្រាំមួយ) ខែ បន្ទាប់ពីកិច្ចសន្យាដើមចូលជាធរមាន និងស្ថិតក្នុងឆ្នាំថវិកាតែមួយ

- តម្លៃឯកតាស្មើឬទាបជាងតម្លៃឯកតាក្នុងកិច្ចសន្យាដើម និង

- តម្លៃសរុបមិនលើសពី ២៥ (ម្ភៃប្រាំ) ភាគរយនៃតម្លៃកិច្ចសន្យាដើម ។

គ- ការចុះកិច្ចសន្យាជាមួយនឹងអង្គភាពជំនាញនៃស្ថាប័នរដ្ឋ ជាវិធីសាស្ត្រលទ្ធកម្មដែលតម្រូវឲ្យចរចាថ្លៃនិងបច្ចេកទេសផ្ទាល់ជាមួយនឹងអង្គភាពជំនាញរបស់ស្ថាប័នរដ្ឋដែលមានធនធាន គ្រឿងចក្រ ឧបករណ៍ សម្ភារៈ និងកម្លាំងពលកម្មគ្រប់គ្រាន់សម្រាប់អនុវត្តកិច្ចសន្យា ។

ឃ- ការចុះកិច្ចសន្យាជាមួយនឹងសហគមន៍ ជាវិធីសាស្ត្រលទ្ធកម្មដែលត្រូវបានប្រើសំដៅលើកទឹកចិត្តសហគមន៍ក្នុងស្រុក ដើម្បីប្រើប្រាស់កម្លាំងពលកម្ម ចំណេះដឹង និងសម្ភារៈ ក្នុងស្រុកសម្រាប់ចូលរួមក្នុងការអភិវឌ្ឍសហគមន៍ ។

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL

# ជំពូកទី ៥
# លទ្ធកម្មសេវាទីប្រឹក្សា

**មាត្រា ១៤.-**

ទីប្រឹក្សាអាចត្រូវបានជ្រើសរើស ដើម្បីផ្ដល់សេវាឯកទេសសម្រាប់គ្រប់គ្រងគម្រោង អនុវត្តកិច្ចសន្យាសំខាន់ៗ ឬផ្ដល់យោបល់ជំនាញក្នុងការងារពង្រឹងពង្រីកស្ថាប័នឬបង្កើនសមត្ថភាព ។ ទីប្រឹក្សាអាចជាក្រុមហ៊ុនទីប្រឹក្សាឬទីប្រឹក្សាឯកត្តជន ។

**មាត្រា ១៥.-**

ក្រុមហ៊ុនទីប្រឹក្សាត្រូវបានជ្រើសរើស នៅពេលស្ថាប័នអនុវត្តលទ្ធកម្មមានតម្រូវការសេវាទីប្រឹក្សាច្រើនដែលមានការពាក់ព័ន្ធគ្នាក្នុងពេលតែមួយ ។ ការជ្រើសរើសក្រុមហ៊ុនទីប្រឹក្សាត្រូវផ្អែកលើសំណើបច្ចេកទេសនិងសំណើហិរញ្ញវត្ថុរបស់ក្រុមហ៊ុនទីប្រឹក្សានីមួយៗ ។

**មាត្រា ១៦.-**

ទីប្រឹក្សាឯកត្តជនត្រូវបានជ្រើសរើសដោយផ្អែកលើលក្ខណសម្បត្តិរបស់ទីប្រឹក្សាសម្រាប់ផ្ដល់សេវាជូនស្ថាប័នអនុវត្តលទ្ធកម្ម ។

**មាត្រា ១៧.-**

វិធីសាស្ត្រជ្រើសរើសទីប្រឹក្សា រួមមាន :

- ការជ្រើសរើសផ្អែកលើគុណភាព
- ការជ្រើសរើសផ្អែកលើគុណភាពនិងថ្លៃ
- ការជ្រើសរើសផ្អែកលើថវិកាកំណត់
- ការជ្រើសរើសផ្អែកលើថ្លៃទាបបំផុត
- ការជ្រើសរើសផ្អែកលើការចរចាផ្ទាល់
- ការជ្រើសរើសផ្អែកលើលក្ខណសម្បត្តិ ។

**មាត្រា ១៨.-**

វិធីសាស្ត្រជ្រើសរើសផ្អែកលើគុណភាព ត្រូវបានប្រើសម្រាប់ជ្រើសរើសក្រុមហ៊ុនទីប្រឹក្សា ។ វិធីសាស្ត្រនេះត្រូវបានអនុវត្ត នៅពេលស្ថាប័នអនុវត្តលទ្ធកម្មមានតម្រូវការសេវាទីប្រឹក្សាច្រើនដែលមានការពាក់ព័ន្ធគ្នាក្នុងពេលតែមួយ និងផ្ដោតជាសំខាន់លើកម្រិតបច្ចេកទេសនៃសេវាទាំងនោះ ។

**មាត្រា ១៩.-**

វិធីសាស្ត្រជ្រើសរើសផ្អែកលើគុណភាពនិងថ្លៃ ត្រូវបានប្រើសម្រាប់ជ្រើសរើសក្រុមហ៊ុនទីប្រឹក្សា នៅពេលស្ថាប័នអនុវត្តលទ្ធកម្មមានការថ្លឹងថ្លែងពីគុណភាពនិងថ្លៃ ស្របតាមកម្រិតបច្ចេកទេសស្មុគស្មាញនៃសេវាដែលត្រូវការ ។

**មាត្រា ២០.-**

វិធីសាស្ត្រជ្រើសរើសផ្អែកលើថវិកាកំណត់ ត្រូវបានប្រើសម្រាប់ជ្រើសរើសក្រុមហ៊ុនទីប្រឹក្សា នៅពេលដែលស្ថាប័នអនុវត្តលទ្ធកម្មមានថវិកាក្នុងកម្រិតមួយកំណត់និងមានទិសដៅច្បាស់លាស់ ។ ស្ថាប័នអនុវត្តលទ្ធកម្មត្រូវបញ្ជាក់ឲ្យបានច្បាស់ពីចំនួនថវិកាដែលមាន ដើម្បីឲ្យក្រុមហ៊ុនទីប្រឹក្សាដាក់សំណើបច្ចេកទេសតម្រូវតាមចំនួនថវិកានោះ ។

**មាត្រា ២១.-**

វិធីសាស្ត្រជ្រើសរើសផ្អែកលើថ្លៃទាបបំផុត ត្រូវបានប្រើសម្រាប់ជ្រើសរើសក្រុមហ៊ុនទីប្រឹក្សា ។ វិធីសាស្ត្រនេះត្រូវបានអនុវត្ត នៅពេលស្ថាប័នអនុវត្តលទ្ធកម្មមានតម្រូវការសេវាទីប្រឹក្សាដែលមានលក្ខណៈជាបទដ្ឋាន និងមានការរៀបចំបានល្អ ។

**មាត្រា ២២.-**

វិធីសាស្ត្រជ្រើសរើសផ្អែកលើការចរចាផ្ទាល់ ត្រូវបានប្រើសម្រាប់ជ្រើសរើសក្រុមហ៊ុនទីប្រឹក្សា ឬទីប្រឹក្សាឯកត្តជននៅក្នុងកាលៈទេសៈពិសេស ។ កាលៈទេសៈពិសេសដែលសមស្របនឹងវិធីសាស្ត្រនេះរួមមាន :

- ការងារបន្តពីមុនដែលត្រូវបានអនុវត្តដោយក្រុមហ៊ុនទីប្រឹក្សាឬទីប្រឹក្សាឯកត្តជន
- ករណីបន្ទាន់បំផុតដែលតម្រូវឲ្យមានការឆ្លើយតបភ្លាមៗ ឬ
- ករណីមានតែក្រុមហ៊ុនមួយឬទីប្រឹក្សាម្នាក់ប៉ុណ្ណោះដែលមានសមត្ថភាពនិងមានបទពិសោធ ។

**មាត្រា ២៣.-**

វិធីសាស្ត្រជ្រើសរើសផ្អែកលើលក្ខណសម្បត្តិ ត្រូវបានប្រើសម្រាប់ជ្រើសរើសទីប្រឹក្សាឯកត្តជន ។ ការជ្រើសរើសតាមវិធីសាស្ត្រនេះ ត្រូវផ្អែកលើចំណេះដឹង កម្រិតជំនាញវិជ្ជាជីវៈ បទពិសោធ និងកម្រិតជំនាញពាក់ព័ន្ធផ្សេងទៀតរបស់ទីប្រឹក្សា ។

**មាត្រា ២៤.-**

ការជ្រើសរើសទីប្រឹក្សា ត្រូវមានការផ្សព្វផ្សាយជាសាធារណៈ ដើម្បីបើកទូលាយឲ្យទីប្រឹក្សាក្នុងស្រុកនិងអន្តរជាតិចូលរួមដាក់សំណើបញ្ជាក់ពីចំណាប់អារម្មណ៍ ។

**មាត្រា ២៥.-**

នីតិវិធីនៃការជ្រើសរើសទីប្រឹក្សា ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

## ជំពូកទី ៦
## លក្ខណសម្បត្តិអ្នកដេញថ្លៃ

**មាត្រា ២៦.-**

គ្រប់អ្នកដេញថ្លៃត្រូវបានផ្តល់ឱកាសដោយយុត្តិធម៌និងស្មើភាពក្នុងការចូលរួមគ្រប់កិច្ចលទ្ធកម្មសាធារណៈ លើកលែងតែអ្នកដេញថ្លៃទាំងឡាយណាដែលកំពុងស្ថិតនៅក្នុងបញ្ជីខ្មៅឬត្រូវបានហាមឃាត់ដោយតុលាការ ។

**មាត្រា ២៧.-**

អ្នកដេញថ្លៃត្រូវចុះបញ្ជីចំណាត់ប្រភេទនិងចំណាត់ថ្នាក់អ្នកដេញថ្លៃនៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីមានសិទ្ធិចូលរួមក្នុងកិច្ចលទ្ធកម្មសាធារណៈ ។ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវធ្វើចំណាត់ប្រភេទនិងចំណាត់ថ្នាក់អ្នកដេញថ្លៃតាមកម្រិតសមត្ថភាពរបស់អ្នកដេញថ្លៃ ដើម្បីធានាការអនុវត្តកិច្ចសន្យា ។ នីតិវិធីនៃការធ្វើចំណាត់ប្រភេទនិងចំណាត់ថ្នាក់អ្នកដេញថ្លៃ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

**មាត្រា ២៨.-**

ការកំណត់បុរេលក្ខណសម្បត្តិអ្នកដេញថ្លៃ ត្រូវធ្វើឡើងដោយស្ថាប័នអនុវត្តលទ្ធកម្មសម្រាប់តែគម្រោងដែលមានលក្ខណៈបច្ចេកទេសស្មុគស្មាញ ។ នីតិវិធីសម្រាប់ធ្វើបុរេលក្ខណសម្បត្តិអ្នកដេញថ្លៃ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

**មាត្រា ២៩.-**

ស្ថាប័នអនុវត្តលទ្ធកម្ម ត្រូវពិនិត្យនិងវាយតម្លៃលើលក្ខណសម្បត្តិតាមក្រោយរបស់អ្នកដេញថ្លៃនាំមុខ មុនការសម្រេចប្រគល់កិច្ចសន្យា ។ នីតិវិធីសម្រាប់កំណត់លក្ខណសម្បត្តិតាមក្រោយ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

**មាត្រា ៣០.-**

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវចុះឈ្មោះអ្នកដេញថ្លៃ អ្នកផ្គត់ផ្គង់ ឬអ្នកទទួលការក្នុងបញ្ជីខ្មៅបន្ទាប់ពីបានរកឃើញថា អ្នកដេញថ្លៃ អ្នកផ្គត់ផ្គង់ ឬអ្នកទទួលការប្រព្រឹត្តល្មើសនឹងបទប្បញ្ញត្តិនៃច្បាប់នេះ ឬបទប្បញ្ញត្តិផ្សេងទៀតដែលពាក់ព័ន្ធនឹងលទ្ធកម្មសាធារណៈ ។

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវជម្រះចេញពីបញ្ជីខ្មៅឈ្មោះអ្នកដេញថ្លៃ អ្នកផ្គត់ផ្គង់ ឬអ្នកទទួលការដែលផុតសុពលភាពក្នុងបញ្ជីខ្មៅ ។

ការចុះនិងការជម្រះបញ្ជីខ្មៅ ត្រូវផ្សព្វផ្សាយជាសាធារណៈ និងត្រូវចម្លងជូនគ្រប់ស្ថាប័នអនុវត្តលទ្ធកម្មក្នុងព្រះរាជាណាចក្រកម្ពុជា ។

នីតិវិធីនៃការចុះ ការជម្រះ និងការផ្សព្វផ្សាយបញ្ជីខ្មៅ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

## ជំពូកទី ៧
## ផែនការលទ្ធកម្ម

**មាត្រា ៣១.-**

គ្រប់ស្ថាប័នអនុវត្តលទ្ធកម្ម ត្រូវរៀបចំផែនការលទ្ធកម្មប្រចាំឆ្នាំ ។ ផែនការលទ្ធកម្មត្រូវមានសង្គតិភាពនឹងកញ្ចប់ថវិកាប្រចាំឆ្នាំ ។

រាល់គម្រោងចំណាយដែលត្រូវអនុវត្តកិច្ចលទ្ធកម្ម ត្រូវកត់ត្រាបញ្ចូលក្នុងផែនការលទ្ធកម្ម ។ ករណីដែលមិនមានការកត់ត្រាក្នុងផែនការលទ្ធកម្ម មិនត្រូវបានអនុញ្ញាតឲ្យផ្តល់ការចំណាយឡើយ ។

នីតិវិធីនៃការរៀបចំផែនការលទ្ធកម្ម ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា ៣២.-**

ស្ថាប័នអនុវត្តលទ្ធកម្ម ត្រូវចងជាកញ្ចប់លទ្ធកម្ម ចំពោះមុខសញ្ញាលទ្ធកម្មដែលស្ថិតក្នុងប្រភេទដូចគ្នា មានលក្ខណៈដូចគ្នាឬប្រហាក់ប្រហែលគ្នា ស្របតាមតម្រូវការជាក់ស្តែងសម្រាប់ធ្វើកិច្ចលទ្ធកម្មតែមួយលើក ដើម្បីបង្កើនកម្រិតគុណភាពនៃការប្រកួតប្រជែង ការសន្សំសំចៃសោហ៊ុយចំណាយ និងចំណេញពេលវេលា ។

**មាត្រា ៣៣.-**

ហាមបំបែកគម្រោងជាគម្រោងតូចៗក្នុងគោលបំណងបំពានវិធីសាស្ត្រលទ្ធកម្ម ឬតម្រូវតាមសិទ្ធិសម្រេចរបស់ស្ថាប័នអនុវត្តលទ្ធកម្ម ។

**មាត្រា ៣៤.-**

ផែនការលទ្ធកម្មត្រូវបានអនុញ្ញាតឲ្យកែតម្រូវក្នុងករណីចាំបាច់ ។ រាល់ការកែតម្រូវផែនការលទ្ធកម្មដោយសារមិនមានពេលវេលាគ្រប់គ្រាន់សម្រាប់អនុវត្តកិច្ចលទ្ធកម្មឬដើម្បីតម្រូវតាមកិច្ចលទ្ធកម្មដែលបានអនុវត្តរួច ត្រូវហាមឃាត់ ។

**មាត្រា ៣៥.-**

ស្ថាប័នអនុវត្តលទ្ធកម្ម ត្រូវផ្ញើផែនការលទ្ធកម្មប្រចាំឆ្នាំទៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីពិនិត្យនិងអនុម័តឲ្យបានមុនថ្ងៃទី ៣១ ខែ ធ្នូ មុនឆ្នាំអនុវត្តថវិកា ។

**មាត្រា ៣៦.-**

ស្ថាប័នអនុវត្តលទ្ធកម្ម ត្រូវអនុវត្តតាមផែនការលទ្ធកម្មប្រចាំឆ្នាំ ដែលបានអនុម័តដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងត្រូវធ្វើរបាយការណ៍លទ្ធកម្មជូនក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុឲ្យបានទៀងទាត់ ។

## ជំពូកទី ៨
## នីតិវិធីនៃការអនុវត្តកិច្ចលទ្ធកម្ម

**មាត្រា ៣៧.-**

អង្គភាពលទ្ធកម្ម ត្រូវអនុវត្តកិច្ចលទ្ធកម្មស្របតាមផែនការលទ្ធកម្មនិងឯកសារដេញថ្លៃដែលបានទទួលទិដ្ឋាការយល់ព្រមរួចហើយ ។

**មាត្រា ៣៨.-**

អង្គភាពលទ្ធកម្មនៃស្ថាប័នអនុវត្តលទ្ធកម្មត្រូវរៀបចំសេចក្តីជូនដំណឹងស្តីពីការដេញថ្លៃសម្រាប់ផ្សព្វផ្សាយដើម្បីជ្រើសរើសអ្នកដេញថ្លៃ ។ សេចក្តីជូនដំណឹងស្តីពីការដេញថ្លៃត្រូវមានព័ត៌មានសំខាន់ៗដូចខាងក្រោម :

- ការពណ៌នាអំពីប្រភេទនិងបរិមាណនៃទំនិញ ការងារសាងសង់ ការងារជួសជុល ឬសេវាកម្ម
- ឈ្មោះ អាសយដ្ឋាន អ៊ីមែល ទូរស័ព្ទ និងទូរសាររបស់អង្គភាពលទ្ធកម្ម
- វិធីសាស្ត្រលទ្ធកម្មដែលត្រូវអនុវត្ត
- លក្ខខណ្ឌតម្រូវនានានៃលក្ខណសម្បត្តិឬបុរេលក្ខណសម្បត្តិ
- កាលបរិច្ឆេទលក់ ទទួល និងបើកឯកសារដេញថ្លៃឬឯកសារកំណត់បុរេលក្ខណសម្បត្តិ
- ការបញ្ជាក់អំពីលក្ខខណ្ឌតម្រូវនៃប្រាក់កក់ធានាការដេញថ្លៃនិងប្រាក់កក់ធានាការអនុវត្តកិច្ចសន្យា ។

**មាត្រា ៣៩.-**

អង្គភាពលទ្ធកម្ម ត្រូវរៀបចំឯកសារដេញថ្លៃឲ្យស្របតាមបទប្បញ្ញត្តិនៃច្បាប់នេះ ដោយបញ្ជាក់ពីលក្ខខណ្ឌតម្រូវនិងលក្ខណវិនិច្ឆ័យនៃការជ្រើសរើសអ្នកដេញថ្លៃឲ្យបានច្បាស់លាស់ សម្រាប់ដាក់ជូនប្រធានស្ថាប័នអនុវត្តលទ្ធកម្មពិនិត្យនិងចុះហត្ថលេខា ។ ចំពោះកិច្ចលទ្ធកម្មដែលត្រូវពិនិត្យនិងសម្រេចដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្ថាប័នអនុវត្តលទ្ធកម្មត្រូវស្នើសុំទិដ្ឋាការយល់ព្រមលើឯកសារដេញ

ថ្លៃពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។ គំរូឯកសារដេញថ្លៃត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

កិច្ចលទ្ធកម្មដែលត្រូវពិនិត្យនិងសម្រេចដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុមិនគ្របដណ្តប់ទៅលើកិច្ចលទ្ធកម្មដែលអនុវត្តដោយឃុំ សង្កាត់ឡើយ ។

**មាត្រា ៤០.-**

សេចក្តីជូនដំណឹងស្តីពីបុរេលក្ខណសម្បត្តិ ការដេញថ្លៃ និងសេចក្តីកែសម្រួលនានា ត្រូវប្រកាសផ្សព្វផ្សាយតាមគេហទំព័រលទ្ធកម្មសាធារណៈ និងតាមសារព័ត៌មាន ហើយត្រូវបិទផ្សាយនៅលើក្តារបិទផ្សាយព័ត៌មានរបស់ស្ថាប័នអនុវត្តលទ្ធកម្ម ។

**មាត្រា ៤១.-**

ឯកសារដេញថ្លៃ ត្រូវផ្សព្វផ្សាយលើគេហទំព័រលទ្ធកម្មសាធារណៈ ។ ស្ថាប័នអនុវត្តលទ្ធកម្មត្រូវរៀបចំឯកសារដេញថ្លៃឲ្យបានគ្រប់គ្រាន់ សម្រាប់លក់ជូនអ្នកដែលមានបំណងចូលរួមដេញថ្លៃ ។

បែបបទនិងការកំណត់ថ្លៃលក់ឯកសារដេញថ្លៃ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

**មាត្រា ៤២.-**

ប្រសិនបើមានការស្នើសុំបំភ្លឺជាលាយលក្ខណ៍អក្សរពីអ្នកដេញថ្លៃណាមួយអំពីឯកសារដេញថ្លៃ ស្ថាប័នអនុវត្តលទ្ធកម្មត្រូវឆ្លើយតបជាលាយលក្ខណ៍អក្សរទៅគ្រប់អ្នកដេញថ្លៃដែលបានទទួលឯកសារដេញថ្លៃ ។ ក្នុងករណីចាំបាច់ ស្ថាប័នអនុវត្តលទ្ធកម្មត្រូវធ្វើការប្រជុំមុនកាលបរិច្ឆេទឈប់ទទួលសំណើដេញថ្លៃ ដើម្បីឆ្លើយបំភ្លឺដោយអញ្ជើញអ្នកដេញថ្លៃដែលបានទទួលឯកសារដេញថ្លៃមកចូលរួម ។

**មាត្រា ៤៣.-**

អង្គភាពលទ្ធកម្មត្រូវទទួល ចុះបញ្ជី និងរៀបចំរក្សាទុកសំណើដេញថ្លៃដែលដាក់ក្នុងស្រោមសំបុត្របិទភ្ជិត នៅកន្លែងមានសុវត្ថិភាព ដោយមិនត្រូវប៉ះពាល់ឲ្យខូចទម្រង់ដើមនៃស្រោមសំបុត្រដាក់សំណើដេញថ្លៃនោះទេ មុនកាលបរិច្ឆេទបើកសំណើដេញថ្លៃ ។ រាល់សំណើដេញថ្លៃត្រូវភ្ជាប់មកជាមួយនូវឯកសារប្រាក់កក់ធានាការដេញថ្លៃ លើកលែងតែសំណើដេញថ្លៃនៃកិច្ចលទ្ធកម្មដែលត្រូវអនុវត្តតាមវិធីសាស្ត្រស្ទង់តម្លៃ ។ ប្រាក់កក់ធានាការដេញថ្លៃ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

**មាត្រា ៤៤.-**

សំណើដេញថ្លៃទាំងអស់ត្រូវបើកជាសាធារណៈភ្លាមៗ បន្ទាប់ពីកាលបរិច្ឆេទឈប់ទទួលសំណើដេញថ្លៃ ។ ព័ត៌មានសំខាន់ៗនៃសំណើដេញថ្លៃនីមួយៗ ត្រូវប្រកាសនៅចំពោះមុខអ្នកចូលរួមបើកសំណើ

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL

ដេញថ្លៃ និងត្រូវកត់ត្រាក្នុងកំណត់ហេតុបើកសំណើដេញថ្លៃ រួចចម្លងជូនគ្រប់អ្នកដេញថ្លៃនិងអ្នកចូលរួមបើកសំណើដេញថ្លៃទាំងអស់ ។

ប្រសិនបើក្នុងដំណើរការដេញថ្លៃលើកដំបូងទទួលបានសំណើដេញថ្លៃតិចជាងបី គណៈកម្មាធិការលទ្ធកម្មមិនត្រូវបើកសំណើដេញថ្លៃទាំងនោះឡើយ ហើយត្រូវបញ្ជូនត្រឡប់ទៅឲ្យអ្នកដេញថ្លៃវិញ ។

ក្នុងករណីដែលដំណើរការដេញថ្លៃលើកដំបូងទទួលបានសំណើដេញថ្លៃតិចជាងបី ដូចបានកំណត់ក្នុងកថាខណ្ឌទី២ខាងលើ ឬពុំទទួលបានសំណើដេញថ្លៃ ឬពុំមានសំណើដេញថ្លៃណាមួយឆ្លើយតបនឹងលក្ខខណ្ឌនៃការដេញថ្លៃនោះ ត្រូវដំណើរការដេញថ្លៃឡើងវិញ ។

ក្នុងដំណើរការដេញថ្លៃឡើងវិញ ទោះបីទទួលបានសំណើដេញថ្លៃចំនួនប៉ុន្មានក៏ដោយ ក៏ត្រូវតែដំណើរការបើកសំណើដេញថ្លៃទាំងនោះតាមកាលបរិច្ឆេទកំណត់ ។

**មាត្រា ៤៥.-**

គណៈកម្មាធិការលទ្ធកម្មត្រូវពិនិត្យ វាយតម្លៃលើសំណើដេញថ្លៃទាំងអស់ជាសម្ងាត់ ។ លក្ខខណ្ឌនិងលក្ខណវិនិច្ឆ័យដែលមានចែងក្នុងឯកសារដេញថ្លៃ ព័ត៌មានប្ដឹងជំទាស់ និងកំណត់ហេតុបើកសំណើដេញថ្លៃ គឺជាមូលដ្ឋានសម្រាប់វាយតម្លៃប្រគល់កិច្ចសន្យា ។ លក្ខខណ្ឌនិងលក្ខណវិនិច្ឆ័យបន្ថែមដែលមិនមានចែងក្នុងឯកសារដេញថ្លៃ មិនត្រូវបានអនុញ្ញាតឲ្យប្រើប្រាស់ក្នុងការវាយតម្លៃឡើយ ។ នីតិវិធីវាយតម្លៃលើសំណើដេញថ្លៃ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

**មាត្រា ៤៦.-**

មុននឹងចាប់ផ្ដើមត្រួតពិនិត្យនិងវាយតម្លៃលើសំណើដេញថ្លៃនៃកិច្ចលទ្ធកម្មនីមួយៗ សមាជិកគណៈកម្មាធិការលទ្ធកម្មដែលត្រូវចូលរួមវាយតម្លៃប្រគល់កិច្ចសន្យា ត្រូវចុះហត្ថលេខាលើសេចក្ដីប្រកាសស្ដីពីក្រមសីលធម៌លទ្ធកម្មដូចមានចែងក្នុងជំពូកទី ១១ នៃច្បាប់នេះ ។

**មាត្រា ៤៧.-**

បន្ទាប់ពីបញ្ចប់ការវាយតម្លៃជ្រើសរើសអ្នកដេញថ្លៃ ស្ថាប័នអនុវត្តលទ្ធកម្មត្រូវចេញសេចក្ដីជូនដំណឹងស្ដីពីការសម្រេចប្រគល់កិច្ចសន្យាទៅឲ្យអ្នកដេញថ្លៃឈ្នះ ដោយចម្លងជូនទៅគ្រប់អ្នកដេញថ្លៃចាញ់ ។ ចំពោះកិច្ចលទ្ធកម្មដែលត្រូវពិនិត្យនិងសម្រេចដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ការចេញសេចក្ដីជូនដំណឹងស្ដីពីការសម្រេចប្រគល់កិច្ចសន្យា ត្រូវធ្វើឡើងក្រោយពេលមានការឯកភាពពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

កិច្ចលទ្ធកម្មដែលត្រូវពិនិត្យនិងសម្រេចដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ លើកលែងតែកិច្ចលទ្ធកម្មដែលអនុវត្តដោយរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវកំណត់ដោយប្រកាសរួមរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនិងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

**មាត្រា ៤៨.-**

ប្រសិនបើមិនមានការជំទាស់តវ៉ាណាមួយក្នុងរយៈពេល ១០ (ដប់) ថ្ងៃនៃថ្ងៃធ្វើការ បន្ទាប់ពីការចេញសេចក្តីជូនដំណឹងស្តីពីការសម្រេចប្រគល់កិច្ចសន្យា អង្គភាពលទ្ធកម្មត្រូវស្នើឲ្យអ្នកដេញថ្លៃឈ្នះផ្តល់នូវឯកសារប្រាក់កក់ធានាការអនុវត្តកិច្ចសន្យា និងត្រូវរៀបចំកិច្ចសន្យាលទ្ធកម្មដូចមានចែងក្នុងជំពូកទី ៩ នៃច្បាប់នេះ ។

**មាត្រា ៤៩.-**

ការចុះហត្ថលេខាលើកិច្ចសន្យាលទ្ធកម្ម ត្រូវធ្វើឡើងរវាងប្រធានស្ថាប័នអនុវត្តលទ្ធកម្មនិងអ្នកដេញថ្លៃឈ្នះ ។ ក្នុងករណីដែលកិច្ចលទ្ធកម្មត្រូវពិនិត្យនិងសម្រេចដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ កិច្ចសន្យាលទ្ធកម្មត្រូវមានការចុះហត្ថលេខាបញ្ជាក់ការយល់ព្រមបន្ថែមដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

**មាត្រា ៥០.-**

ស្ថាប័នអនុវត្តលទ្ធកម្ម ត្រូវចាត់ចែងគ្រប់គ្រងកិច្ចសន្យា ដើម្បីធានាឲ្យការអនុវត្តកិច្ចសន្យាប្រព្រឹត្តទៅបានត្រឹមត្រូវស្របតាមលក្ខខណ្ឌដូចមានចែងក្នុងកិច្ចសន្យា ។

**មាត្រា ៥១.-**

លទ្ធកម្មតាមប្រព័ន្ធអេឡិចត្រូនិច ត្រូវធ្វើឡើងតាមរយៈប្រព័ន្ធអ៊ិនធើណែត នៅពេលដែលប្រព័ន្ធព័ត៌មានវិទ្យាក្នុងព្រះរាជាណាចក្រកម្ពុជាត្រូវបានប្រើប្រាស់ទូលំទូលាយនិងមានភាពរឹងមាំ ។ នីតិវិធីនៃការអនុវត្តកិច្ចលទ្ធកម្មតាមប្រព័ន្ធអេឡិចត្រូនិច ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

**មាត្រា ៥២.-**

កិច្ចលទ្ធកម្មសាធារណៈជាកម្មវត្ថុនៃការធ្វើសវនកម្មនិងអធិការកិច្ចដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ ដោយអនុលោមតាមបទប្បញ្ញត្តិនៃច្បាប់នេះ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមានដទៃទៀត ។

## ជំពូកទី ៩
## កិច្ចសន្យាលទ្ធកម្ម

**មាត្រា ៥៣.-**

ការរៀបចំកិច្ចសន្យាលទ្ធកម្ម ត្រូវអនុលោមតាមបទប្បញ្ញត្តិនៃច្បាប់នេះ និងស្របតាមលក្ខខណ្ឌដែលមានចែងក្នុងឯកសារដេញថ្លៃ ព្រមទាំងស្របតាមគំរូកិច្ចសន្យាដែលត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL

**មាត្រា ៥៤.-**

កិច្ចសន្យាលទ្ធកម្មត្រូវធ្វើជាភាសាខ្មែរ ។ ក្នុងករណីចាំបាច់ កិច្ចសន្យាអាចសរសេរជាភាសាបរទេស ដោយត្រូវបកប្រែចេញពីកិច្ចសន្យាជាភាសាខ្មែរ ។ ក្នុងករណីមានខ្លឹមសារមិនស្របគ្នារវាងភាសាខ្មែរនិងភាសាបរទេស កិច្ចសន្យាជាភាសាខ្មែរជាឯកសារផ្លូវការ ។

**មាត្រា ៥៥.-**

គ្រប់កិច្ចសន្យាលទ្ធកម្មត្រូវទូទាត់ជាប្រាក់រៀល លើកលែងតែកិច្ចសន្យាសម្រាប់អនុវត្តគម្រោងលទ្ធកម្មនៅក្រៅប្រទេស ដែលអាចអនុញ្ញាតឲ្យទូទាត់ជារូបិយបណ្ណបរទេស ។

**មាត្រា ៥៦.-**

លក្ខណៈបច្ចេកទេសទំនិញ សំណង់ ឬសេវាកម្មដែលចែងក្នុងកិច្ចសន្យាត្រូវតែដូចគ្នានឹងលក្ខណៈបច្ចេកទេសដែលមានចែងក្នុងឯកសារដេញថ្លៃ ។

**មាត្រា ៥៧.-**

តម្លៃកិច្ចសន្យាមិនត្រូវលើសពីតម្លៃដេញឈ្នះ ក្រោយការកែតម្រូវលេខគណិត ។ តម្លៃកិច្ចសន្យាជាតម្លៃថេរក្នុងអំឡុងពេលអនុវត្តកិច្ចសន្យា លើកលែងតែក្នុងកាលៈទេសៈពិសេសខ្លះ តម្លៃកិច្ចសន្យាអាចកែប្រែបាន ដោយមានការអនុញ្ញាតជាមុនពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។ កាលៈទេសៈពិសេសដែលតម្លៃកិច្ចសន្យាអាចកែប្រែបាន ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

**មាត្រា ៥៨.-**

រាល់កិច្ចសន្យាត្រូវមានប្រាក់កក់ធានាការអនុវត្តកិច្ចសន្យា លើកលែងតែកិច្ចសន្យាដែលទទួលបានតាមរយៈវិធីសាស្ត្រលទ្ធកម្មស្ទង់តម្លៃ កិច្ចសន្យាជាមួយនឹងទីប្រឹក្សាឯកត្តជន និងកិច្ចសន្យាជាមួយនឹងអង្គភាពជំនាញនៃស្ថាប័នរដ្ឋ ។ អ្នកដេញថ្លៃឈ្នះ ត្រូវកក់ប្រាក់ធានាការអនុវត្តកិច្ចសន្យាមុនពេលកិច្ច-សន្យាចូលជាធរមាន ។ ចំនួនប្រាក់កក់ធានាការអនុវត្តកិច្ចសន្យា ត្រូវស្មើនឹងចំនួនដែលបានចែងក្នុងឯកសារដេញថ្លៃ ។ ប្រាក់កក់ធានាការអនុវត្តកិច្ចសន្យា ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

ប្រាក់កក់ធានាការអនុវត្តកិច្ចសន្យាត្រូវរឹបអូសបង់ចូលថវិការដ្ឋ ប្រសិនបើអ្នកដេញថ្លៃឈ្នះបដិសេធការអនុវត្តកិច្ចសន្យាដែលបានចូលជាធរមានឬបំពានលក្ខខណ្ឌកិច្ចសន្យា ហើយត្រូវស្ថាប័នអនុវត្តលទ្ធកម្មបញ្ឈប់កិច្ចសន្យាមុនកាលកំណត់ ។

ប្រាក់កក់ធានាការអនុវត្តកិច្ចសន្យាត្រូវមានសុពលភាពរហូតដល់ចប់រយៈពេលធានាគុណភាពទំនិញ សំណង់ ឬសេវាកម្ម ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

**មាត្រា ៥៩.-**

ការប្រគល់ទទួល ត្រូវធ្វើឡើងឲ្យបានត្រឹមត្រូវតាមទំហំ បរិមាណ គុណភាព លក្ខណៈបច្ចេកទេស និងស្របតាមពេលវេលាដែលបានកំណត់ក្នុងកាលវិភាគប្រគល់ទទួល ដូចមានចែងក្នុងកិច្ចសន្យានិងត្រូវស្ថិតក្រោមការត្រួតពិនិត្យរបស់គណៈកម្មការប្រគល់ទទួល ។

នីតិវិធីនៃការបង្កើតគណៈកម្មការប្រគល់ទទួល ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

**មាត្រា ៦០.-**

ស្ថាប័នអនុវត្តលទ្ធកម្មត្រូវរៀបចំការទូទាត់តម្លៃកិច្ចសន្យាជូនអ្នកផ្គត់ផ្គង់ទំនិញ អ្នកទទួលការសំណង់ ឬអ្នកផ្តល់សេវាកម្ម ដោយផ្អែកលើលក្ខខណ្ឌទូទាត់ក្នុងកិច្ចសន្យា ។

**មាត្រា ៦១.-**

អ្នកដេញថ្លៃឈ្នះ អាចចុះកិច្ចសន្យាបន្តដើម្បីផ្តល់ផ្នែកខ្លះនៃគម្រោងទៅឲ្យភាគីទីបី ប៉ុន្តែត្រូវមានការយល់ព្រមជាលាយលក្ខណ៍អក្សរជាមុនរបស់ស្ថាប័នអនុវត្តលទ្ធកម្ម ។ ក្នុងករណីដែលកិច្ចសន្យាលទ្ធកម្មត្រូវពិនិត្យនិងសម្រេចដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្ថាប័នអនុវត្តលទ្ធកម្មត្រូវស្នើសុំការយល់ព្រមពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

ក្នុងករណីដែលអ្នកដេញថ្លៃឈ្នះត្រូវបានអនុញ្ញាតឲ្យចុះកិច្ចសន្យាបន្តជាមួយភាគីទីបី អ្នកដេញថ្លៃឈ្នះត្រូវទទួលខុសត្រូវចំពោះមុខស្ថាប័នអនុវត្តលទ្ធកម្មលើការអនុវត្តកិច្ចសន្យាទាំងមូល ។

## ជំពូកទី ១០
## ការដោះស្រាយវិវាទនិងបណ្តឹងតវ៉ា

**មាត្រា ៦២.-**

សាមីស្ថាប័នអនុវត្តលទ្ធកម្មមានសមត្ថកិច្ចទទួលពិនិត្យនិងដោះស្រាយបណ្តឹងតវ៉ារបស់អ្នកដេញថ្លៃ នៅដំណាក់កាលនីមួយៗនៃកិច្ចលទ្ធកម្ម ។

អ្នកប្តឹងដែលមិនយល់ព្រមនឹងសេចក្តីសម្រេចរបស់សាមីស្ថាប័នអនុវត្តលទ្ធកម្ម អាចប្តឹងទៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីពិនិត្យនិងដោះស្រាយ ។

បែបបទនិងនីតិវិធីនៃការប្តឹង និងការដោះស្រាយបណ្តឹងនៅស្ថាប័នអនុវត្តលទ្ធកម្មនិងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ៦៣.-**

អ្នកប្តឹងដែលមិនយល់ព្រមនឹងសេចក្តីសម្រេចរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អាចប្តឹងទៅតុលាការមានសមត្ថកិច្ចនៃព្រះរាជាណាចក្រកម្ពុជា ។

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL

## ជំពូកទី ១១
## ក្រមសីលធម៌លទ្ធកម្ម

**មាត្រា ៦៤.-**

ក្នុងពេលដំណើរការលទ្ធកម្មសាធារណៈ ប្រធាន អនុប្រធាន និងសមាជិកនៃគណៈកម្មាធិការលទ្ធកម្ម មន្ត្រីលទ្ធកម្ម អ្នកដេញថ្លៃ ព្រមទាំងមន្ត្រីនិងបុគ្គលដទៃទៀត ដែលមានការពាក់ព័ន្ធនឹងកិច្ចលទ្ធកម្មត្រូវគោរពតាមក្រមសីលធម៌លទ្ធកម្ម ។

ក្រមសីលធម៌លទ្ធកម្ម ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

## ជំពូកទី ១២
## ទោសប្បញ្ញត្តិ

**មាត្រា ៦៥.-**

អ្នករាជការសាធារណៈគ្រប់លំដាប់ថ្នាក់ ដែលបានប្រព្រឹត្តល្មើសនឹងបទប្បញ្ញត្តិនៃច្បាប់នេះ ឬត្រូវបានរកឃើញថា មានការពាក់ព័ន្ធនឹងការប្រព្រឹត្តមិនប្រក្រតីនៅក្នុងដំណើរការលទ្ធកម្មសាធារណៈ ត្រូវទទួលទណ្ឌកម្មខាងរដ្ឋបាលស្របតាមច្បាប់និងបទប្បញ្ញត្តិជាធរមាន ។ ទណ្ឌកម្មខាងរដ្ឋបាលនេះ មិនមែនជាឧបសគ្គសម្រាប់ការចោទប្រកាន់និងការផ្តន្ទាទោសព្រហ្មទណ្ឌស្របតាមច្បាប់និងបទប្បញ្ញត្តិជាធរមាននៃព្រះរាជាណាចក្រកម្ពុជាឡើយ ។

**មាត្រា ៦៦.-**

អ្នកដេញថ្លៃ អ្នកទទួលការ ឬអ្នកផ្គត់ផ្គង់ដែលត្រូវបានរកឃើញថា មានការពាក់ព័ន្ធនឹងអំពើពុករលួយ អំពើបន្លំ អំពើឃុបឃិត ឬអំពើបង្ខិតបង្ខំនៅក្នុងដំណើរការលទ្ធកម្មសាធារណៈ ឬផ្តល់ភស្តុតាងក្លែងបន្លំឬមិនត្រឹមត្រូវក្នុងពេលដាក់ពាក្យប្តឹងតវ៉ានៅក្នុងដំណើរការលទ្ធកម្ម ត្រូវបញ្ឈប់ជាបន្ទាន់ពីក្នុងលទ្ធកម្មសាធារណៈដែលកំពុងដំណើរការ ឬលុបកិច្ចសន្យាដែលកំពុងអនុវត្តភ្លាមៗ និងត្រូវកត់ត្រាចូលបញ្ជីខ្មៅ ។

ទណ្ឌកម្មនេះ មិនមែនជាឧបសគ្គសម្រាប់ការចោទប្រកាន់និងការផ្តន្ទាទោសព្រហ្មទណ្ឌស្របតាមច្បាប់និងបទប្បញ្ញត្តិជាធរមាននៃព្រះរាជាណាចក្រកម្ពុជាឡើយ ។

**មាត្រា ៦៧.-**

អ្នករាជការសាធារណៈគ្រប់លំដាប់ថ្នាក់ អ្នកដេញថ្លៃ អ្នកទទួលការ អ្នកផ្គត់ផ្គង់ និងបុគ្គលពាក់ព័ន្ធផ្សេងទៀត ដែលត្រូវបានរកឃើញថា បានប្រព្រឹត្តអំពើពុករលួយ អំពើបន្លំ អំពើឃុបឃិត ឬអំពើបង្ខិតបង្ខំនៅក្នុងដំណើរការលទ្ធកម្មសាធារណៈ ត្រូវផ្តន្ទាទោសដោយយោងតាមក្រមព្រហ្មទណ្ឌនិងបទប្បញ្ញត្តិជាធរមាននៃព្រះរាជាណាចក្រកម្ពុជា ។

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL

ព្រះបរមរាជវាំង

**មាត្រា ៦៨.-**

អំពើប្រព្រឹត្តនៅក្នុងដំណើរការលទ្ធកម្មសាធារណៈតាមការដេញថ្លៃ ដើម្បីកម្ចាត់អ្នកដេញថ្លៃឬធ្វើឲ្យខូចការដេញថ្លៃ ដោយអំណោយ ការសន្យា ការព្រមព្រៀង ឬតាមគ្រប់មធ្យោបាយទុច្ចរិតដទៃទៀត ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ (ប្រាំមួយ) ខែ ទៅ ២ (ពីរ) ឆ្នាំ និងពិន័យជាប្រាក់ពី ១ ០០០ ០០០ (មួយលាន) រៀល ទៅ ៤ ០០០ ០០០ (បួនលាន) រៀល ។

**មាត្រា ៦៩.-**

អំពើប្រព្រឹត្តនៅក្នុងដំណើរការលទ្ធកម្មសាធារណៈតាមការដេញថ្លៃ ដើម្បីធ្វើជាឧបសគ្គដល់សេរីភាពនៃការដេញថ្លៃ ដោយហិង្សា ដោយការបង្ខិតបង្ខំ ឬដោយការគំរាមកំហែង ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ឆ្នាំ ទៅ ៣ (បី) ឆ្នាំ និងពិន័យជាប្រាក់ពី ២ ០០០ ០០០ (ពីរលាន) រៀល ទៅ ៦ ០០០ ០០០ (ប្រាំមួយលាន) រៀល ។

**មាត្រា ៧០.-**

ការប៉ុនប៉ងប្រព្រឹត្តបទមជ្ឈិមដែលមានចែងក្នុងមាត្រា ៦៨ និងមាត្រា ៦៩ នៃច្បាប់នេះ ត្រូវផ្តន្ទាទោសដូចគ្នានឹងការប្រព្រឹត្តបទមជ្ឈិមនោះបានសម្រេចដែរ ។

**មាត្រា ៧១.-**

ចំពោះបទមជ្ឈិមដែលមានចែងក្នុងមាត្រា ៦៨ និងមាត្រា ៦៩ នៃច្បាប់នេះ ទោសបន្ថែមមួយឬច្រើនដូចមានចែងក្នុងមាត្រា ៥៣ (ប្រភេទនៃទោសបន្ថែម) នៃក្រមព្រហ្មទណ្ឌអាចត្រូវបានប្រកាស ។

**មាត្រា ៧២.-**

នីតិបុគ្គលអាចត្រូវប្រកាសថា ត្រូវទទួលខុសត្រូវព្រហ្មទណ្ឌតាមលក្ខខណ្ឌដែលមានចែងក្នុងមាត្រា ៤២ (ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល) នៃក្រមព្រហ្មទណ្ឌ ចំពោះបទមជ្ឈិមដែលមានចែងក្នុងមាត្រា ៦៨ និងមាត្រា ៦៩ នៃច្បាប់នេះ ។

នីតិបុគ្គលត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ២០ ០០០ ០០០ (ម្ភៃលាន) រៀល ទៅ ១០០ ០០០ ០០០ (មួយរយលាន) រៀល ព្រមទាំងទោសបន្ថែមមួយឬច្រើនដូចមានចែងក្នុងមាត្រា ១៦៨ (ទោសបន្ថែមអនុវត្តចំពោះនីតិបុគ្គល) នៃក្រមព្រហ្មទណ្ឌ ។

**មាត្រា ៧៣.-**

បទល្មើសពុករលួយដែលមានចែងក្នុងច្បាប់នេះ និងក្នុងច្បាប់និងបទប្បញ្ញត្តិជាធរមានដទៃទៀតនៃព្រះរាជាណាចក្រកម្ពុជា ក៏ស្ថិតនៅក្រោមសមត្ថកិច្ចរបស់អង្គភាពប្រឆាំងអំពើពុករលួយដែលជាអង្គភាពតែមួយគត់ មានសមត្ថកិច្ចស៊ើបអង្កេត និងកសាងសំណុំរឿងពុករលួយទៅតុលាការ ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

អង្គភាពនិងបុគ្គលដទៃទៀត ដែលបានដឹងពីបទល្មើសពុករលួយទាំងឡាយណាដែលមានចែងក្នុងច្បាប់នេះ និងក្នុងច្បាប់និងបទប្បញ្ញត្តិជាធរមានដទៃទៀតនៃព្រះរាជាណាចក្រកម្ពុជា ត្រូវប្ដឹងទៅអង្គភាព ឬការិយាល័យរាជធានី ខេត្ត ប្រឆាំងអំពើពុករលួយ អំពីរឿងហេតុនៃបទល្មើសទាំងនេះ។

## ជំពូកទី១៣

## អន្តរប្បញ្ញត្តិ

**មាត្រា ៧៤.-**

អនុក្រឹត្យលេខ១០៥ អនក្រ.បក ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០០៦ស្ដីពីលទ្ធកម្មសាធារណៈ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងលទ្ធកម្មសាធារណៈដែលនៅជាធរមាន នៅមានសុពលភាពហូតដល់មានលិខិតបទដ្ឋានគតិយុត្តថ្មីមកជំនួសស្របតាមស្មារតីនៃច្បាប់នេះ។

## ជំពូកទី១៤

## អវសានប្បញ្ញត្តិ

**មាត្រា ៧៥.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៧៦.-**

ច្បាប់នេះត្រូវប្រកាសជាការប្រញាប់។

ធ្វើនៅព្រះបរមរាជវាំងថ្ងៃទី ១៤ ខែ មករា ឆ្នាំ ២០១២

**ព្រះហស្តលេខា និងព្រះរាជលញ្ជករ**

**នរោត្តម សីហមុនី**

នស.១២០១.០៤១

បានយកសេចក្ដីក្រាបបង្គំទូលថ្វាយ
សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ
**នាយករដ្ឋមន្ត្រី**
**ហត្ថលេខា**
**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានជម្រាបជូនសម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
**ហត្ថលេខា**
**គាត ឈន់**

លេខ: ៣៤ ច.ល
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ មករា ឆ្នាំ២០១២
**អគ្គលេខាធិការរងទី១រាជរដ្ឋាភិបាល**

**ស៊យ សុខា**

# សទ្ទានុក្រមជាឧបសម្ព័ន្ធនៃ
# ច្បាប់ស្តីពីលទ្ធកម្មសាធារណៈ

- **លទ្ធកម្ម** សំដៅដល់ការទិញឬការរកបាននូវទំនិញ សំណង់ សេវាកម្ម ឬសេវាទីប្រឹក្សាតាមរយៈវិធីសាស្ត្រដែលមានចែងក្នុងច្បាប់នេះ ។

- **កិច្ចលទ្ធកម្ម** សំដៅដល់ដំណើរការលទ្ធកម្មចាប់ពីពេលរៀបចំឯកសារដេញថ្លៃរហូតដល់ពេលទទួលបានទំនិញ សំណង់ សេវាកម្ម ឬសេវាទីប្រឹក្សា ។

- **លទ្ធកម្មសាធារណៈ** សំដៅដល់កិច្ចលទ្ធកម្មដែលធ្វើឡើងដោយក្រសួង ស្ថាប័ន រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ សហគ្រាសសាធារណៈ គ្រឹះស្ថានសាធារណៈរដ្ឋបាល អង្គភាពស្វយ័តភាពហិរញ្ញវត្ថុដទៃទៀត និងដៃគូឯកជនសាធារណៈ ។

- **ស្ថាប័នអនុវត្តលទ្ធកម្ម** សំដៅដល់ក្រសួង ស្ថាប័ន រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ សហគ្រាសសាធារណៈ គ្រឹះស្ថានសាធារណៈរដ្ឋបាល និងអង្គភាពស្វ័យភាពហិរញ្ញវត្ថុដទៃទៀត និងដៃគូឯកជនសាធារណៈដែលអនុវត្តកិច្ចលទ្ធកម្មសាធារណៈ ។

- **អង្គភាពថវិកា** សំដៅដល់អង្គភាពដែលមានសមត្ថភាពក្នុងការទទួលខុសត្រូវនិងមានភាពជាម្ចាស់ក្នុងការអនុវត្តសកម្មភាពការងារក្នុងការរៀបចំនិងគ្រប់គ្រងថវិកា ព្រមទាំងក្នុងការត្រួតពិនិត្យលទ្ធផលនៃការអនុវត្តសកម្មភាពការងារនិងការអនុវត្តថវិកាដោយខ្លួនឯង ស្របតាមគោលការណ៍ និងនីតិវិធីរបស់ក្រសួង ស្ថាប័ន ។

- **មន្ត្រីលទ្ធកម្ម** សំដៅដល់ប្រធាន អនុប្រធាន និងមន្ត្រីទាំងអស់របស់អង្គភាពលទ្ធកម្មនៃស្ថាប័នអនុវត្តលទ្ធកម្ម ។

- **ការដេញថ្លៃ** សំដៅដល់ដំណើរការលទ្ធកម្មដែលសំណើដេញថ្លៃត្រូវបានដាក់ ទទួល និងវាយតម្លៃសម្រាប់គោលបំណងប្រគល់កិច្ចសន្យា ។

- **ឯកសារដេញថ្លៃ** សំដៅដល់សំណុំឯកសារដែលអង្គភាពលទ្ធកម្មបានរៀបចំនិងផ្តល់ជាដំបូងទៅឲ្យអ្នកដេញថ្លៃ ដើម្បីប្រើសម្រាប់រៀបចំសំណើដេញថ្លៃ ដែលរួមមានពាក្យសុំដេញថ្លៃ សេចក្តីអញ្ជើញឲ្យចូលរួមដេញថ្លៃ ការស្នើឲ្យដាក់សំណើ សេចក្តីអញ្ជើញឲ្យចូលរួមក្នុងការកំណត់បុរេលក្ខណសម្បត្តិ សេចក្តីណែនាំចំពោះអ្នកដេញថ្លៃ លក្ខណៈបច្ចេកទេស ទំហំការងារ លក្ខខណ្ឌយោង និងលក្ខខណ្ឌនៃកិច្ចសន្យា ។

- **សំណើដេញថ្លៃ** សំដៅដល់សំណុំឯកសាររួមមានឯកសារដេញថ្លៃដែលបានបំពេញដោយអ្នកដេញថ្លៃ និងឯកសារភ្ជាប់មួយចំនួនទៀតដូចមានតម្រូវក្នុងឯកសារដេញថ្លៃ ដែលអ្នកដេញថ្លៃបានដាក់នៅស្ថាប័នអនុវត្តលទ្ធកម្ម សម្រាប់គោលបំណងផ្គត់ផ្គង់ទំនិញ ទទួលការសំណង់ ផ្តល់សេវាកម្មឬសេវាទីប្រឹក្សា ។

- **ទំនិញ** សំដៅដល់វត្ថុរាវ រឹង ឧស្ម័នដែលមានតម្លៃ ឬផលប្រយោជន៍សេដ្ឋកិច្ចដូចជាគ្រឿងចក្រ ឧបករណ៍ សម្ភារៈ បរិក្ខារ គ្រឿងឧបភោគបរិភោគ ឱសថ និងផលិតផលផ្សេងៗ រួមទាំងអគ្គិសនីផងដែរ ។

- **សំណង់** សំដៅដល់រាល់សកម្មភាពដែលពាក់ព័ន្ធនឹងការងារសាងសង់ ការងារជួសជុល ការធ្វើឡើងជាថ្មី ការដំឡើង ការជីក ការបូម និងការងារប្រហាក់ប្រហែល ដែលបង្កើតឲ្យមានការប្រើប្រាស់កម្លាំងពលកម្ម គ្រឿងម៉ាស៊ីន បរិក្ខារ និងបច្ចេកវិទ្យា ។

- **សេវាកម្ម** សំដៅដល់សកម្មភាពដែលពាក់ព័ន្ធនឹងការប្រើប្រាស់កម្លាំងមនុស្ស គ្រឿងបរិក្ខារ ឬបច្ចេកវិទ្យាដែលនាំមកនូវផលប្រយោជន៍ដល់ស្ថាប័នសាធារណៈ ប៉ុន្តែមិនរាប់បញ្ចូលការងារសាងសង់និងសេវាទីប្រឹក្សាទេ ។

- **អ្នកដេញថ្លៃ** សំដៅដល់រូបវន្តបុគ្គលឬនីតិបុគ្គលដែលមានបំណងចូលរួមក្នុងកិច្ចលទ្ធកម្មសាធារណៈ និងបានដាក់សំណើដេញថ្លៃឬសំណើបញ្ជាក់ពីចំណាប់អារម្មណ៍ ។

- **អ្នកដេញថ្លៃនាំមុខ** សំដៅដល់អ្នកដេញថ្លៃដែលបានចូលរួមដេញថ្លៃ ហើយសំណើដេញថ្លៃរបស់ខ្លួនត្រូវបានគណៈកម្មាធិការលទ្ធកម្មវាយតម្លៃថាជាសំណើដេញថ្លៃឆ្លើយតបសមស្របជាងគេ មុនពេលធ្វើលក្ខណសម្បត្តិតាមក្រោយ ។

- **សេវាទីប្រឹក្សា** សំដៅដល់សេវាជំនាញការដែលផ្តល់ដោយក្រុមហ៊ុនទីប្រឹក្សាឬទីប្រឹក្សាឯកត្តជនដែលពាក់ព័ន្ធនឹងគម្រោងណាមួយឬសម្រាប់ការពង្រឹងពង្រីកស្ថាប័នឬបង្កើនសមត្ថភាព ។

- **ទីប្រឹក្សា** សំដៅដល់ទីប្រឹក្សាឯកត្តជនឬក្រុមហ៊ុនទីប្រឹក្សាដែលមានមុខរបរផ្តល់សេវាផ្នែកបញ្ញា ។ ក្រុមហ៊ុនទីប្រឹក្សាអាចជាក្រុមហ៊ុនពាណិជ្ជកម្មឬនីតិបុគ្គលផ្សេងទៀត ។

- **អ្នកផ្គត់ផ្គង់** សំដៅដល់ឯកត្តបុគ្គលឬក្រុមហ៊ុនដែលចុះកិច្ចសន្យាលក់ទំនិញជាមួយនឹងស្ថាប័នអនុវត្តលទ្ធកម្ម ។

- **អ្នកទទួលការ** សំដៅដល់ឯកត្តបុគ្គល ក្រុមហ៊ុន ឬទីប្រឹក្សាដែលចុះកិច្ចសន្យាលើការងារសាងសង់ ការងារជួសជុល សេវាកម្ម ឬសេវាទីប្រឹក្សាជាមួយនឹងស្ថាប័នអនុវត្តលទ្ធកម្ម ។

- **មុខសញ្ញាលទ្ធកម្ម** សំដៅដល់មុខទំនិញ សំណង់ សេវាកម្ម ឬសេវាទីប្រឹក្សាដែលជាកម្មវត្ថុនៃការដេញថ្លៃ ពិគ្រោះថ្លៃ ស្ទង់តម្លៃ ឬការចរចាថ្លៃ ។

- **អញ្ញាប់លទ្ធកម្ម** សំដៅដល់ការប្រមូលផ្តុំមុខសញ្ញាលទ្ធកម្មដែលមានប្រភេទដូចគ្នា លក្ខណៈដូចគ្នា ឬប្រហាក់ប្រហែលគ្នាបញ្ចូលក្នុងក្រុមតែមួយ សម្រាប់ធ្វើលទ្ធកម្មតែមួយលើក ។

- **ក្រមសីលធម៌លទ្ធកម្ម** សំដៅដល់ក្រមដែលអ្នកចូលរួមពាក់ព័ន្ធនឹងកិច្ចលទ្ធកម្មសាធារណៈត្រូវយល់ដឹងនិងអនុវត្តដោយស្មោះត្រង់តាមបទប្បញ្ញត្តិគតិយុត្តជាធរមាន និងអនុវត្តឲ្យបានត្រឹមត្រូវតាមតួនាទីនិងមុខងាររបស់ខ្លួន។

- **សវនកម្ម** សំដៅដល់ការត្រួតពិនិត្យជាទៀងទាត់រៀងរាល់ឆ្នាំដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុលើគ្រប់កិច្ចលទ្ធកម្មសាធារណៈដែលបានអនុវត្តរួចនិងស្ថិតក្រោមសិទ្ធិសម្រេចរបស់ស្ថាប័នអនុវត្តលទ្ធកម្ម ។

- **បញ្ជីខ្មៅ** សំដៅដល់បញ្ជីហាមឃាត់ការចូលរួមរបស់អ្នកដេញថ្លៃក្នុងដំណើរការលទ្ធកម្មសាធារណៈដែលសម្រេចដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

- **អំពើបន្លំ** សំដៅដល់ការបកស្រាយបំភ្លៃហេតុការណ៍ ដើម្បីធ្វើឲ្យមានឥទ្ធិពលលើដំណើរការលទ្ធកម្មសាធារណៈ ។

- **អំពើឃុបឃិត** សំដៅដល់ផែនការឬការរៀបចំឡើងរវាងអ្នកដេញថ្លៃពីរឬច្រើននាក់ ដើម្បីបង្កើតតម្លៃដេញថ្លៃសិប្បនិម្មិតគ្មានលក្ខណៈប្រកួតប្រជែងពិតប្រាកដ ឬធ្វើឲ្យមានឥទ្ធិពលលើសកម្មភាពរបស់ភាគីណាមួយ ក្នុងដំណើរការលទ្ធកម្មសាធារណៈឬធ្វើឲ្យមានការជះឥទ្ធិពលលើការអនុវត្តកិច្ចសន្យា ។

- **អំពើបង្ខិតបង្ខំ** សំដៅដល់ការហាមឃាត់ឬការគម្រាមកំហែងដោយផ្ទាល់ឬដោយប្រយោលធ្វើឲ្យមានគ្រោះថ្នាក់ដល់បុគ្គលឬទ្រព្យសម្បត្តិរបស់បុគ្គល ដើម្បីធ្វើឲ្យមានឥទ្ធិពលដល់ការចូលរួមក្នុងដំណើរការលទ្ធកម្មសាធារណៈរបស់បុគ្គលនោះ ឬធ្វើឲ្យមានការជះឥទ្ធិពលលើការអនុវត្តកិច្ចសន្យា។